សលាកប័ត្រព័ត៌មាន NEWSLETTER
លេខៈ ៤៧ ខែវិច្ឆកា ឆ្នាំ២០០៩
Issue: 47 November 2009

ឃ្លាំមើល សាលាក្តីខ្មែរក្រហម
KHMER ROUGE TRIBUNAL (KRT) WATCH

គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ_សមាគមការពារសិទ្ធិមនុស្សកម្ពុជា
CAMBODIAN HUMAN RIGHTS ACTION COMMITTEE
ADHOC - CARAM - CCPCR - CDP - CHHRA - CKIMHRDA - CSD - CWCC - GENEROUS - HROTP - IDA - KKKHRO - KKKHRDA - KID - KIND - KSA - KYA - LAC - PDP -PJJ - VIGILANCE

# សង្គមស៊ីវិលគិតគូរអំពីៈ “សំណងសំរាប់ជនរងគ្រោះ នៃរបបខ្មែរក្រហម”
## Civil Society Considers Reparations for Victims of the Khmer Rouge Regime

កាលពីខែវិច្ឆិកា ឆ្នាំ២០០៨ កន្លងទៅ គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃអង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) និងអង្គភាពជនរងគ្រោះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានរៀបចំនូវសន្និសីទអន្តរជាតិជាលើកដំបូងគេដើម្បីបើកឱកាសឱ្យមានជជែកពិភាក្សាយ៉ាងទូលំទូលាយអំពី *សំណង និង ក្របខ័ណ្ឌនៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* ។



*វេទិកាពិភាក្សា ស្តីពីមធ្យោបាយជាក់ស្តែងឈានទៅរកការអនុវត្តន៍សំណង*

នៅមួយឆ្នាំបន្ទាប់មកទៀតនេះ គណៈកម្មាធិការប្រព្រឹត្តិកម្ម បានរួមសហការគ្នាជាមួយនឹងអង្គការ Redress ក៏បានរៀបចំឱ្យមានសិក្ខាសាលាមួយទៀត ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ នៅទីក្រុងភ្នំពេញ និងបានបញ្ចេញនូវឯកសារពិគ្រោះពិភាក្សាមួយ ដើម្បីជាការគិតគូរបន្ថែមទៀតស្របតាមស្ថានភាពដែលបានវិវត្តន៍ប្រែប្រួល និង ដើម្បីលើកទឹកចិត្តឱ្យមានការជជែកពិភាក្សាបន្ថែមទៀត ពីសំណាក់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ នៅជំហានបន្ទាប់មកទៀតនេះ ក្នុងគោលបំណងដើម្បីធ្វើឱ្យទស្សនៈវិស័យ និងការប្រមើលមើលអំពី *"សំណងសម្រាប់ជនរងគ្រោះនៃរបបខ្មែរក្រហម"* ឱ្យអាចអនុវត្តន៍ទៅបានជាក់ស្តែងយ៉ាងពិតប្រាកដ ។

វាគ្មិននៅក្នុងសិក្ខាសាលានេះយល់ស្របគ្នាថា *ការទាមទារសំណងពីសំណាក់ជនរងគ្រោះ គឺជាសិទ្ធិ* ដែលត្រូវបានចែងទទួលស្គាល់ នៅក្នុងក្របខ័ណ្ឌអន្តរជាតិ ដូចនេះ ការទទួលស្គាល់នូវសិទ្ធិនេះ ក៏ត្រូវចាំបាច់ឱ្យមានដែរ ដើម្បីជួយជួសជុលនូវភាពរងគ្រោះដោយសារអំពើឧក្រិដ្ឋកម្ម ដែលបានកើតឡើងក្នុងរបបខ្មែរក្រហមជូនជនរងគ្រោះ ។

ជាការពិត ចៅក្រម នៃ អង្គជំនុំជម្រះវិសាមញ្ញ បានគិតគូរយ៉ាងច្បាស់លាស់រួចមកហើយអំពី អាណត្តិនៃសំណងតាមរយៈការអនុម័តនូវវិធានផ្ទៃក្នុងដែល *"អនុញ្ញាតឱ្យជនរងគ្រោះស្វែងរកសំណងសមូហភាព និងសំណងផ្លូវចិត្ត"*។ នៅក្នុងបរិបទជាក់ស្តែង អង្គជំនុំជម្រះវិសាមញ្ញនេះដើរតួនាទីយ៉ាងសំខាន់ និងជាកត្តាលីករមួយ នៅក្នុងដំណើរការគិតគូរឱ្យមានសំណងសំរាប់ជនរងគ្រោះ ទោះបីជា មានភាគីពាក់ព័ន្ធផ្សេងៗដទៃទៀតក្តី វាក៏ត្រូវការចាំបាច់ឱ្យមានការចូលរួមពី សំណាក់រាជរដ្ឋាភិបាលកម្ពុជា, ជនរងគ្រោះ និងសមាគមជនរងគ្រោះ, ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកចូលរួមវិភាគទានដទៃផ្សេងទៀតដែរ ។

កាលពីខែកញ្ញា ឆ្នាំ២០០៩ នៅក្នុងកិច្ចប្រជុំពេញអង្គចៅក្រមកន្លងទៅនេះ ចៅក្រម នៃអង្គជំនុំជម្រះវិសាមញ្ញ បានប្រកាសថា គេនឹងអាចណែនាំអំពីវិសោធនកម្មសំខាន់ៗជាមូលដ្ឋានមួយចំនួនទាក់ទិននឹងការចូលរួមរបស់ជនរងគ្រោះ នៅក្នុងដំណើរការនីតិវិធីរបស់សាលាក្តីនេះ។ ការផ្លាស់ប្តូរនោះទំនងជានឹងអាចប៉ះពាល់ផងដែរនូវ វិធានផ្ទៃក្នុងបច្ចុប្បន្នដែលកំពុងតែមានចែងអំពីបញ្ហាសំណង។ ដូចនេះ គណៈកម្មាធិការប្រព្រឹត្តិកម្ម និងអង្គការ Redress សូមរំលឹកថា តុលាការនេះ គឺជាតួអង្គជានិមិត្តរូបគន្លឹះមួយដែលមាននៅទីនេះ ដើម្បីផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ និងវាក៏ចាំបាច់ឱ្យតុលាការនេះធ្វើការបកស្រាយនូវគ្រប់ទិដ្ឋភាពទាំងអស់នៃអាណត្តិការងាររបស់ខ្លួន( រួមទាំងបញ្ហាសំណងនេះផង) ។ ជនរងគ្រោះ គឺជាគន្លឹះឈានទៅរកការបង្កើត ឱ្យមានមរតកដ៏សំខាន់សំរាប់ប្រទេសកម្ពុជារបស់យើងផងដែរ ។

ដូចនេះ គណៈកម្មាធិការប្រព្រឹត្តិកម្ម និងអង្គការ **Redress** បានស្នើសុំឱ្យចៅក្រមអង្គជំនុំជម្រះវិសាមញ្ញ មេត្តាធ្វើការពិចារណានូវ អនុសាសន៍សំខាន់ៗ ដូចខាងក្រោមៈ

១- នៅជិតចុងបញ្ចប់នៃសំណុំរឿង ០០១ នេះ គេត្រូវការឱ្យចៅក្រមទាំងអស់រៀបចំនូវដីកាបង្គាប់សំណងដោយបញ្ជាក់ ឱ្យបានកាន់តែច្បាស់លាស់នូវអាណត្តិរបស់គេក្នុងការចេញនូវ *សំណងជាសមូហភាព និងសំណងផ្លូវ*

*ចិត្ត* ហើយចៅក្រម ក៏ត្រូវបកស្រាយបន្ថែមទៀតអំពីការអនុវត្តន៏សំណងជាក់ ស្ដែង ថាតើត្រូវធ្វើឡើងតាមរបៀបណាផងដែរ ។

២- អង្គជំនុំជម្រះនេះ គួរតែពិភាក្សាឱ្យបានទូលំទូលាយ និងទាក់ទាញឱ្យមានការចូលរួមរបស់ជនរងគ្រោះ នៅគ្រប់តំណាក់កាលទាំងអស់នៃដំណើរការគិតគូរអំពីសំណងនេះ ។

៣- សំណងបែបណាក៏ដោយ ទោះបីជាសំណងភាគច្រើនដែល មានលក្ខណៈជានិមិត្តរូប ក៏នៅតែត្រូវការឱ្យមានថវិកាដែរ ។ ដូចនេះ តុលាការត្រូវការគិតគូរអំពីបញ្ហានេះថែមទៀត គឺថា តុលាការមានភារកិច្ចធានាថាសេចក្ដីសំរេចអំពីសំណងត្រូវ តែមានភាពជាក់ស្ដែងនិងមានប្រសិទ្ធភាព និងអាចអនុវត្តន៏បាន ។ ដូចនេះតុលាការគួរតែគិរគូរផងដែរនូវមធ្យោបាយ ស្វែងរកថវិកាផ្សេងៗដែលអាចធ្វើទៅបាន ទាំងនៅក្នុងក្របខ័ណ្ឌរបស់តុលាការ ក៏ដូចជានៅក្រៅតុលាការ ព្រមទាំងអំពី លទ្ធភាពទទួលបាននូវប្រភពថវិកា ទោះបីជា តិចតួចបំផុតក្ដី ពីថ្នាក់ប្រជាពលរដ្ឋកម្ពុជានៅតាមសហគមន៏ រហូតដល់ ថ្នាក់រាជរដ្ឋាភិបាល និងអ្នកជំនួញ និងប្រភពថវិកាឯកជន ដទៃទៀតផងដែរ ។

ជាមួយនឹងការគិតគូរ និងការពិភាក្សាជាច្រើនលើកច្រើនសានាពេលកន្លងមកនេះ អង្គការសង្គមស៊ីវិលបានប្រមើលឃើញថា ឆ្នាំ២០១០ ខាងមុខ គឺជាឆ្នាំដ៏មានសារៈសំខាន់សំរាប់ឱ្យអង្គជំនុំជម្រះ វិសាមញ្ញធ្វើការឆ្លុះបញ្ចាំងនូវការងារបច្ចុប្បន្នភាព ក៏ដូចជាត្រៀមជា ស្រេចចំពោះបញ្ហាប្រឈមមុខនានា ដែលអាចកើតឡើងនាពេលខាង មុខទៀត ។ ជាងនេះទៅទៀត ចៅក្រមទាំងអស់គួរតែប្រើប្រាស់នូវពេលវេលានៅបន្ទាប់ពីការបញ្ចប់សាលក្រមនៃសំណុំរឿង ០០១ ដើម្បី ធ្វើការពិភាក្សាជាមួយនឹងភាគីពាក់ព័ន្ធដទៃទៀត ក៏ដូចជា អ្នកជំនាញការ ព្រមទាំងអ្នកផ្សេងទៀត អំពីទិសដៅអនាគត ស្ដីពីការគិតគូរអំពី បញ្ហាសំណងដែលមានលក្ខណៈអាចបត់បែនបាន និងមានន័យពេញលេញដើម្បីជាផលប្រយោជន៏ដល់ជនរងគ្រោះនៅក្នុងរបបខ្មែរក្រហមទាំងមូល ។

## សប្ដាហ៍ចុងក្រោយដើម្បីបញ្ចប់សំណុំរឿង "ឌុច"

### Last Week for Concluding Duch's Trial

បន្ទាប់ពីសំរាកមួយរយៈដើម្បីត្រៀមរៀបចំនូវអំណះអំណាងផ្នែកច្បាប់ជាលើកចុងក្រោយរួចមក អង្គជំនុំជម្រះសាលាដំបូងបាន បើកសវនាការជាបន្តទៀតទៅលើសំណុំរឿង ០០១ ដែលមានជនជាប់ចោទឈ្មោះ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ដែលជាអតីតប្រធានមន្ទីរ ស-២១ នៅក្នុងកំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

កាលពីនៅពេលធ្វើសវនាការទៅលើអង្គសេចក្ដី ដែលមានរយៈពេល ២១ សប្ដាហ៍ កន្លងមកនេះ យើងសង្កេតឃើញមានសាក្សី ចំនួន៤៧នាក់ ដែលជាសាក្សីបញ្ជាក់អង្គហេតុ និងអ្នកជំនាញ ព្រមទាំង សាក្សីជាដើមបណ្ដឹងរដ្ឋប្បវេណីចំនួន២២រូបផងដែរ ។ ជនជាប់ចោទ រូបនេះ ត្រូវបានតុលាការចោទប្រកាន់ពី **បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, អំពើបំពារបំពាននឹងអនុសញ្ញាទីក្រុងហ្សឺណែវ** (**ឧក្រិដ្ឋកម្មសង្គ្រាម**), **អំពើមនុស្សឃាត និងអំពើទារុណកម្ម** ។

សវនាការលើកចុងក្រោយនេះ គឺជាពេលវេលាដ៏សំខាន់សំរាប់ឱ្យភាគីនៅក្នុងរឿងក្ដីនេះ រួមមានដូចជាៈ ខាងភាគីដើមបណ្ដឹងរដ្ឋប្បវេណី (តំណាងដោយក្រុមមេធាវី), សហព្រះរាជអាជ្ញា និង ជនជាប់ចោទ **ឌុច** (ការពារក្ដីដោយសហមេធាវីការពារ) លើកបង្ហាញ ជូនអង្គចៅក្រមទាំង ៥រូប នូវសេចក្ដីសន្និដ្ឋានផ្នែកច្បាប់ជាចុងក្រោយ បន្ទាប់ពីការលើកអំណះអំណាង និង ការបង្ហាញនូវសក្ខីកម្មជាច្រើន កាលពីរយៈពេលប៉ុន្មានខែមុននេះ ។



*ជនជាប់ចោទ ឌុច បង្ហាញខ្លួននៅក្នុងសវនាការ*

យោងតាមការបញ្ជាក់របស់លោក **រាជ សម្បត្តិ** ប្រធានកិច្ចការសាធារណៈ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺថា សវនាការលើសេចក្ដីសន្និដ្ឋានរបស់ភាគីនេះមានសារៈសំខាន់ណាស់ ដើម្បីឱ្យអង្គចៅក្រមអាចធ្វើសេចក្ដីសំរេចថាតើ ជនជាប់ចោទ **ឌុច** នេះ មានពិរុទ្ធភាព (មានទោស) ឬគ្មានពិរុទ្ធភាព (គ្មានទោស) ។ ព្រឹត្តិការណ៏នេះមានការចូលរួមយ៉ាងច្រើនពីប្រជាពលរដ្ឋខ្មែរជាជន រងគ្រោះ សិស្សានុសិស្ស និស្សិត មន្ត្រីរាជការបុគ្គលិអង្គការនានា ក៏ដូចជាភ្ញៀវអន្តរជាតិផងដែរ ។

**<u>សង្ខេបសវនាការទៅលើសេចក្តីសន្និដ្ឋានចុងក្រោយៈ</u>**

ភាគីដើមបណ្តឹងរដ្ឋប្បវេណី ដែលមានចំនួន ៩៣ រូប និង តំណាងដោយមេធាវីចំរុះសាសន៍ចំនួន ៤ ក្រុម ត្រូវបានផ្តល់ពេលវេលា ជាបន្តបន្ទាប់ក្នុងការលើកឡើងនូវសេចក្តីសន្និដ្ឋានជាលើកចុងក្រោយ ។ លោកស្រី **ទី ស្រ៊ីណា** តំណាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១បាន លើកឡើងថា *"ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០១ នេះ មានសារៈសំខាន់ណាស់ មិនគ្រាន់តែដើម្បីស្វែងរកយុត្តិធម៌ ចំពោះក្រុមគ្រួសារ សាច់ញាតិ ដែលបានស្លាប់បាត់បង់ជីវិតទេ ប៉ុន្តែថែមទាំងដើម្បីឱ្យអង្គសវនាការទាំងមូលបានឮនូវសំលេងរបស់ជនរងគ្រោះ និងសោកនាដកម្មដែលគាត់បានទទួលក៏ដូចជា ដើម្បីឱ្យចៅក្រមថ្លឹងថ្លែងនូវសេចក្តីឈឺចាប់ទាំងនោះផងដែរ ។"* នៅចុងបញ្ចប់នៃសេចក្តីសន្និដ្ឋានចុងក្រោយរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះ មេធាវី **ម៉ុច សុវណ្ណារី** តំណាងក្រុមទី៣ ក៏បានស្នើសុំដល់អង្គចៅក្រមឱ្យពិចារណាទៅលើការសុំទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដូចជាៈ *ការសុំបង្កើតឱ្យមានមូលនិធិស្ម័គ្រចិត្ត (សម្រាប់ជនរងគ្រោះ), ការស្វែងរកប្រភពថវិកាមកពីខាងក្រៅ (ឧ. ចំណូលពីការចូលទស្សនា សារមន្ទីរទួលស្លែង និងសារមន្ទីរជើងឯក, វិភាគទានពីម្ចាស់ជំនួយជាតិ និងអន្តរជាតិ), ការរក្សានូវទ្រង់ទ្រាយកន្លែងធ្វើទារុណកម្ម រូបគំនូរសំភារៈធ្វើទារុណកម្ម និងកសាងកន្លែងរំលឹកវិញ្ញាណក្ខន្ធ* ជាដើម ។

ភាគីសហព្រះរាជអាជ្ញាអន្តរជាតិ ដែលមានរូបលោកស្រី **ជា លាង** និងលោក **វីល្លៀម ស្មីត** បានគូសបញ្ជាក់នូវចំណុចសំខាន់ៗខាងផ្នែកផ្លូវច្បាប់ អង្គហេតុដែលបានកើតឡើងនៅមន្ទីរស-២១ និងនៅជើងឯក និងទំនាក់ទំនងនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ ជាមួយនឹងថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដែលបានអនុវត្តគោលនយោបាយ ហើយដែលបានបណ្តាលឱ្យមានអ្នកទោស ១២,២៧៣ ស្លាប់ ដោយការធ្វើទារុណកម្ម, ការគំរាមកំហែងផ្លូវចិត្ត និងរូបរាងកាយ, អំពើទាសករ, ការរំលោភបំពានផ្លូវភេទ, មនុស្សឃាត, អំពើបំពារបំពានបែបអមនុស្សធម៌ដទៃទៀត ព្រមទាំងអំពើធ្វើទុក្ខបុកម្នេញផ្សេងទៀតប្រឆាំងជនស៊ីវិល និងឈ្លើយសឹករៀតណាម និងជនបរទេសបស្ចឹមប្រទេស ។ល ។

លោកស្រី **ជា លាង** បានលើកឡើងថា មានតែអង្គជំនុំជម្រះនេះទេ ដែលនឹងត្រូវផ្តល់នូវយុត្តិធម៌ជូនដល់ជនរងគ្រោះទាំងនោះ មិនមែននាំឱ្យមានការសងសឹក ឬបំភ្លេចចោទនូវឧក្រិដ្ឋកម្មទាំងឡាយ ដែលបានកើតឡើង នៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យនោះទេ ។ ដូចនេះ អង្គជំនុំជម្រះមានយុត្តាធិការគ្រប់គ្រាន់ ដើម្បីដាក់ការទទួលខុសត្រូវរបស់ជនជាប់ចោទ **ឌុច** ថាជា មេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ដែលបានកើតឡើងនៅក្នុងមន្ទីរ-ស២១ ព្រោះតែមន្ទីរនេះ មានលក្ខណៈខុសផ្លែកពីមន្ទីរសន្តិសុខដទៃទៀត ដែលមានភារកិច្ចអនុវត្តន៏នូវគោលនយោបាយរបស់បក្សកុម្មុយនីស្ត និងបញ្ជាក់យ៉ាងច្បាស់នូវទំនាក់ទំនងរវាងជនជាប់ចោទ និងថ្នាក់ដឹកនាំនៃគណៈកម្មាធិការមជ្ឈឹមបក្ស ។ ចំណែកសហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំឱ្យតុលាការដាក់ទោសជនជាប់ចោទ៤០ ឆ្នាំ ។

នៅក្នុងសវនាការនោះដែរ **ឌុច** បានបញ្ជាក់នូវគោលជំហររបស់ខ្លួនថា ខ្លួនមានការស្មោះត្រង់ចំពោះបក្ស ដូចនេះ លោកសូមទទួលខុសត្រូវខាងផ្លូវចិត្តចំពោះជនរងគ្រោះកម្ពុជា ហើយលោកពិតជាមានវិប្បដិសារីយ៉ាងធ្ងន់ធ្ងរអស់មួយជីវិត ។ ការពិតបក្សបានឃោសនា ថាខិតខំដើម្បីការពារផលប្រយោជន៏ជាតិ និងប្រជាជនកម្ពុជា ប៉ុន្តែផ្ទុយទៅវិញមិនបានធ្វើដូចនេះទេ ហើយថែមទាំងបានបង្កមហាវិនាសកម្មចំពោះប្រជាជនកម្ពុជាទៀតផង ។ **ឌុច** បានអះអាងជាថ្មីទៀតថា លោកសូមទទួលខុសត្រូវចំពោះអ្នករងគ្រោះនៅមន្ទីរស-២១ និងសុំខមាលទោសចំពោះអ្នកដែលបានស្លាប់ជីវិតទោស ក៏ដូចជាអ្នកនៅរស់រានមានជីវិតដល់សព្វថ្ងៃនេះ ដោយបានទាំងអធិដ្ឋានដល់ព្រះជាម្ចាស់របស់គាត់ទៀតផង ។ **ឌុច** ក៏បានស្នើសុំដល់ជនរងគ្រោះ ដើម្បីសុំឱ្យចំហទ្វារសុំទោសដល់រូបគាត់ សម្រាប់សំដែងនូវវិប្បដិសារីទាំងអស់នេះ ដោយសារតែគាត់បានទទួលស្គាល់ទាំងខាងច្បាប់ និងខាងផ្លូវចិត្តចំពោះការឈឺចាប់នេះហើយ ។ ជាងនេះទៅទៀត គាត់ក៏បាន រំលឹកថាគាត់បានសហការជាមួយតុលាការនេះ និងបានសូមសន្យាថានៅថ្ងៃមុខ ទោះបីយ៉ាងណាក៏ដោយ ក៏គាត់ធ្វើអ្វីមួយដើម្បីប្រជាជន ។

ទោះបីជាសវនាការនេះបានបញ្ចប់នៅក្នុងសប្តាហ៏នេះរួចរាល់ ហើយក៏ដោយ អង្គចៅក្រមទាំងរូប នៅមិនទាន់អាចចេញសាលក្រមភ្លាមៗនេះបានឡើយ ហើយការប្រកាសសាលក្រមចំពោះករណីនេះ នឹងអាចចេញនៅពេលខាងមុខតែមិនទាន់ដឹងថាពេលណានៅឡើយ ។

# ជនរងគ្រោះដោយការបង្ខំឱ្យរៀបការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

## Victims of Forced Marriage under the KR Regime

ជនរងគ្រោះដោយការបង្ខំឱ្យរៀបការ នៅក្រោមរបបខ្មែរក្រហមបានដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជូនទៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកាន់តែច្រើនឡើង ហើយសហចៅក្រមស៊ើបអង្កេត ក៏បាននឹងកំពុងធ្វើការស៊ើបអង្កេតលើរឿងទាំង

នេះផងដែរ។ បន្ទាប់ពីជនរងគ្រោះចំនួន**៧នាក់** ដំបូង បានដាក់ពាក្យបណ្តឹង និងបានក្លាយជាដើមបណ្តឹងរដ្ឋប្បវេណីកាលពីពេល ថ្មីៗរួចមកមានពាក្យបណ្តឹងរបស់ជនរងគ្រោះផ្សេងទៀតបានបញ្ជូនទៅអង្គភាពជនរងគ្រោះ និង ត្រូវបានបញ្ជូនជាបន្តបន្ទាប់សរុបមានចំនួន **៣១នាក់**ហើយ គិតមកត្រឹមដើមខែវិច្ឆិកា ឆ្នាំ២០០៩នេះ។ ភាគច្រើន នៃជនរងគ្រោះមកពីខេត្ត កំពត កោះកុង កំពង់ចាម ពោធិសាត់ កណ្តាល ភ្នំពេញ និងស្វាយរៀង ហើយនឹងមានជនរងគ្រោះនៅតាមបណ្តាខេត្តផ្សេងៗជាបន្តបន្ទាប់ទៀត។

នៅពេលសាកសួរ ឬសំភាសន៍ ជនរងគ្រោះភាគច្រើនបាន រៀបរាប់ពីការរៀបការរបស់ខ្លួន គឺមានលក្ខណៈស្ទើរតែដូចៗគ្នា។ ពួកគាត់ត្រូវបានគេប្រាប់ថាឱ្យមកជួបជុំគ្នានៅកន្លែងមួយដែលបាន កំណត់ដូចជា នៅសាលសហករណ៍ ឬផ្ទះបាយរួម ជាដើម ដោយពុំមាន មូលហេតុច្បាស់លាស់ទេ។ នៅកន្លែង និងឱកាសនៃការរៀបការ នីមួយៗ មានបុរស និងស្ត្រីមិនតិចជាងពី១០គូរ (២០នាក់)ឡើយ ហើយពេលខ្លះមានរហូតរាប់រយនាក់ទៀតផងត្រូវបានរៀបការជាមួយគ្នា។ ភាគច្រើន គូស្រករទាំងនោះមិនដែលបានស្គាល់គ្នាពីមុនមកទេ ឯអ្នកខ្លះគ្រាន់តែធ្លាប់ឃើញរស់នៅក្នុងសហករណ៍ជាមួយគ្នាប៉ុណ្ណោះ។

ពេលនោះ ទោះបីមានជនណាម្នាក់មិនចង់រៀបការ ក៏គ្មានអ្នកណាហ៊ានប្រកែកតវ៉ាជាចំហឡើយ ព្រោះខ្លាចការធ្វើទារុណកម្ម។ បន្ទាប់មកគូរស្រករថ្មីថ្មោងទាំងនោះ ត្រូវបានបញ្ជូនឱ្យរស់នៅក្នុង ខ្ទមឬទីកន្លែងដែលបានកំណត់ក្នុងរយៈពេលជាពីមួយយប់ទៅបីយប់។ អំឡុងពេលរស់នៅជាមួយគ្នានោះ ពួកគេត្រូវបានឃ្លាំមើលពីអ្នកតាមដានរបស់ខ្មែរក្រហម “*ឈ្លប*” ថាតើប្តីប្រពន្ធទើបរៀបការនោះចុះ សំរុងនឹងគ្នា និងធ្វើតាមអង្គការឬទេ។ ជនរងគ្រោះទាំងនោះមិនយូរ មិនឆាប់ បានបង្ខំចិត្តរួមភេទជាមួយដៃគូរបស់គេដោយជៀសវាងការ យកទៅ "*អប់រំរៀនសូត្រ*" ជាពាក្យរបស់ខ្មែរក្រហមប្រើមានន័យថា: ការយកទៅប្រើទារុណកម្ម ឬយកទៅសំលាប់ចោល។ បន្ទាប់មកទៀត ពួកគេត្រូវបានបំបែកឱ្យទៅធ្វើការទៅតាមកន្លែងរៀងៗខ្លួន។

ជាការពិតការរៀបការ ដែលមានទ្រង់ទ្រាយធំបែបនេះ ត្រូវបានឃើញមានធ្វើឡើងនៅទូទាំងប្រទេស ហើយពិធីនៃការរៀបចំ គឺមានលក្ខណៈដូចៗគ្នា ដែលអាចចាត់ទុកថាជាការអនុវត្តន៍គោលនយោបាយជាប្រព័ន្ធរបស់មេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យដោយឱ្យប្តីប្រពន្ធទើបរៀបការរស់នៅជាមួយគ្នា ដើម្បីបង្កើតមនុស្សថ្មីសំរាប់ បដិវត្តរបស់ពួកគេ។ គោលនយោបាយ ប្រជាពលរដ្ឋបែបនោះ ចាត់ទុកជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ជាពិសេសគឺ ការរំលោភផ្លូវភេទ, ទាសភាពផ្លូវភេទ, ការបង្ខំឱ្យមានកូន និងអំពើហិង្សាផ្លូវភេទ ធ្ងន់ធ្ងរផ្សេងៗទៀត។ ការបង្ខំឱ្យរៀបការអាចជាបទល្មើសមួយនៃ ការធ្វើទារុណកម្មផងដែរ។

ដោយពេលវេលានៃការរង់ចាំរបស់ជនរងគ្រោះអស់ពេលជាយូរមកហើយដើម្បីយុត្តិធម៌ ហើយនេះក៏ជាក្តីសង្ឃឹមរបស់ជនរងគ្រោះខាងលើផងដែរ ដោយយោងលើសេចក្តីថ្លែងការណ៍របស់ការិយាល័យ សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កាលពីថ្ងៃទី៥ វិច្ឆិកា ឆ្នាំ២០០៩ ថ្មីៗនេះ ពីការស៊ើបសួរលើករណី០០២ ដោយបានរាប់បញ្ចូលពីការស៊ើបអង្កេត *លើការរៀបកាដោយបង្ខំក្នុងរបបកម្ពុជាប្រជាធិបតេយ្យ* ទៀតផង។ ទន្ទឹមនេះ ពេលវេលាក្នុងការដាក់ពាក្យបណ្តឹងទៅកាន់សាលាក្តីខ្មែរក្រហមនេះក៏កាន់តែខិតមកដល់ទីបញ្ចប់ផងដែរ គឺប្រហែលជារវាងចុងខែធ្នូឆ្នាំ២០០៩ ឬត្រឹមដើមខែមករា ឆ្នាំ២០១០ ខាងមុខនេះប៉ុណ្ណោះ។

ហេតុនេះ **មជ្ឈមណ្ឌលហិង្សាផ្លូវភេទនៃក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា** ជាអង្គការក្រៅរដ្ឋាភិបាលផ្តល់ជំនួយផ្នែកច្បាប់ ដោយមិនយកកម្រៃមានក្រុមមេធាវី ដែលមានបទពិសោធន៏ជួយ ជនរងគ្រោះហិង្សាផ្លូវភេទ សូមស្នើដល់ជនរងគ្រោះដែលមានបំណង ដាក់ពាក្យបណ្តឹងសូមទាក់ទងមកអង្គការ យើងខ្ញុំឱ្យបានរួសរាន់តាមអាសយដ្ឋាន ផ្ទះលេខ:១២, ផ្លូវ២៨២, ស,ក បឹងកេងកង១, ក្រុង ភ្នំពេញ លេខទូរស័ព្ទ: ០១២ ៨០០ ៨១៦ ឬ

Email: savorn@cdpcambodia.org

## ព័ត៌មានសំខាន់:

➢ ប្រសិនបើលោកអ្នកចាប់អារម្មណ៍ចង់ចូលរួមដាក់ពាក្យបណ្តឹង**ជាភាគីដើមបណ្តឹងរដ្ឋប្បវេណី** និង**ជាសាក្សីនៅចំពោះមុខសាលាក្តីខ្មែរក្រហម**

**សូមទាក់ទង:**

- **សមាគមអាដហុក (ADHOC)**
  លេខទូរស័ព្ទ: ០២៣ ៩៩០ ៥៤៤, ០២៣ ២១៨ ៦៥៣
- វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ **(KID)**
  លេខទូរស័ព្ទ: ០២៣ ២១៤ ៩២៨
- មជ្ឈមណ្ឌលអភិវឌ្ឍន៏សង្គម **(CSD)**
  លេខទូរស័ព្ទ: ០២៣ ៣៦៤ ៧៣៥
- សមាគមការពារសិទ្ធិមនុស្សខ្មែរកម្ពុជាក្រោម **(KKKHRA)**
  លេខទូរស័ព្ទ: ០២៣ ៩៩៣ ៤៨៦
- អង្គភាពជនរងគ្រោះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
  លេខទូរស័ព្ទ: ០២៣ ២១៤ ២៩១

➢ ស្តាប់កម្មវិធីឃ្លាំមើលសាលាក្តីដែលមានផ្សាយបន្តផ្ទាល់ និងចាក់ផ្សាយឡើងវិញ តាមវិទ្យុ FM ១០២ រៀងរាល់ ថ្ងៃពុធ ម៉ោង ៥:៣០ - ៦:៣០ ល្ងាច ។
➢ សូមស្រាវជ្រាវព័ត៌មានបន្ថែមលើគេហទំព័រ **www.krtrial.info**

*ទស្សនៈទាំងឡាយដែលមាននៅក្នុងអត្ថបទនៃសលាកប័ត្រព័ត៌មាននេះ មិនមែនឆ្លុះបញ្ចាំងពីទស្សនៈរបស់ ឌី.អ៊ី.ឌី(DED) ទេ។*
**ឧបត្ថម្ភមូលនិធិដោយ: ឌី.អ៊ី.ឌី**